មជ្ឈមណ្ឌលឯកសារកម្ពុជា
គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)
សិក្ខាសាលាជាមួយគ្រូបង្រៀន-ក្រុមការងារស្តីពីការចងក្រងឯកសារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
ប្រាសាទព្រះវិហារ ថ្ងៃទី ២៤-២៦ ខែធ្នូ ឆ្នាំ២០១០

# អត្ថបទពិភាក្សាទី៧

# ហេតុអ្វីត្រូវធ្វើការគ្រប់គ្រងគុណភាព ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ?

*ដោយ ឌី ខាំបូលី*

ដើម្បីធានាឲ្យបានថា ការបង្រៀន«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)»ទទួលបាននូវគោលដៅផ្នែកគរុកោសល្យ និងដើម្បីធានាឲ្យបានថា ការបង្រៀននេះសម្រេចបាននូវគោលបំណងរបស់គម្រោង ក្នុងការនាំមកនូវការផ្សះផ្សាជាតិ ការកសាងសន្តិភាព និងការចូលរួមចំណែកក្នុងការការពារអំពើប្រល័យពូជសាសន៍ជាសាកល កម្មវិធីវាយតម្លៃនៃការគ្រប់គ្រងគុណភាពទូលំទូលាយមួយនឹងត្រូវបានអនុវត្ត។ ការគ្រប់គ្រងគុណភាពនឹងធ្វើការវាយតម្លៃ ទៅលើប្រសិទ្ធភាពនៃវគ្គបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ ដើម្បីសម្រេចឲ្យបាននូវគោលបំណងទាំងនេះ ប្រធានបទចំនួនបួននឹងត្រូវបានធ្វើការវាយតម្លៃ ៖

- ប្រសិទ្ធភាពនៃសៀវភៅ«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)»
- ប្រសិទ្ធភាពនៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន
- ប្រសិទ្ធភាពនៃសៀវភៅលំហាត់សម្រាប់សិស្ស
- ប្រសិទ្ធភាពនៃវគ្គបណ្តុះបណ្តាលគ្រូបង្រៀន

## *ហេតុអ្វីត្រូវធ្វើការគ្រប់គ្រងគុណភាព?*

គ្រូខ្ទេសនិងគ្រូថ្នាក់មូលដ្ឋាន ទោះបីជាបានបញ្ចប់វគ្គបណ្តុះបណ្តាលយ៉ាងណាក៏ដោយ ក៏នៅតែមានការខ្វល់ខ្វាយ មិនត្រឹមតែបញ្ហាសីលធម៌និងសង្គមដ៏ស្មុគស្មាញ សារធាតុនៃភាពសើបផ្នែកនយោបាយក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការខ្វល់ខ្វាយក្នុងការបង្រៀនប្រវត្តិសាស្ត្រនេះប្រកបដោយប្រសិទ្ធភាព។ ថ្នាក់ដឹកនាំក្រសួងអប់រំយុវជននិងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ដូចជា

អ្នកជំនាញជាតិនិងអន្តរជាតិ និងអ្នកអប់រំទាំងអស់ដែលបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលគ្រូ ក៏ចូលរួមចែករំលែកនូវកង្វល់ទាំងអស់នេះដែរ ។ ការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ត្រូវបានធ្វើឡើងភ្លាមៗបន្ទាប់ពីការដួលរលំនៃរបបនេះ នៅក្នុងឆ្នាំ១៩៧៩ ។ ទោះជាយ៉ាងនេះក្តី នេះគឺជាលើកទីមួយហើយដែលក្រសួងកម្ពុជាបានឆ្លងកាត់វគ្គបណ្តុះបណ្តាលដ៏វការមួយក្នុងការអភិវឌ្ឍជំនាញ ដើម្បីបង្ហាត់បង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមថ្នាក់រៀន ប្រកបដោយភាពពិត ឥតលម្អៀង និងចាកឆ្ងាយពីការឃោសនានយោបាយ ។ ការគ្រប់គ្រងគុណភាពដើម្បីការអភិវឌ្ឍន៍ជំនាញ នឹងជួយដោះស្រាយកង្វល់ទាំងអសនេះ គាំទ្រគ្រូដើម្បីពង្រីកសមត្ថភាពបង្រៀនរបស់ខ្លួន និងជួយគ្រូក្នុងការជំនះនូវបញ្ហាប្រឈម ដែលគ្រូនឹងជួបប្រទះនៅក្នុងកំឡុងពេលនៃការបង្រៀន ។ ការគ្រប់គ្រងគុណភាពមានសារសំខាន់ណាស់ ដើម្បីធានានូវប្រសិទ្ធភាពនៃកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងប្រសិទ្ធភាពនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅថ្នាក់មធ្យមសិក្សានៅទូទាំងប្រទេសកម្ពុជា ។

ការគ្រប់គ្រងគុណភាពនឹងពង្រឹងប្រសិទ្ធភាពរបស់គ្រូបង្រៀន និងធានាឲ្យបានថា គ្រូទទួលខុសត្រូវនៅក្នុងនាមជាអ្នកអប់រំប្រកបដោយអាជីពមួយ ដែលកំណត់ការរំពឹងទុករបស់សិស្ស និងតួនាទីនៃការដឹកនាំរបស់ខ្លួន ក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ដំណើរការនៃការគ្រប់គ្រងគុណភាព នឹងផ្តល់ជាអនុសាសន៍ទៅលើចំណុចទាំងឡាយណា ដែលគ្រូអាចទទួលបានប្រយោជន៍ពីវិធីសាស្ត្រក្នុងការបង្រៀន ប្រកបដោយប្រសិទ្ធភាព ។ ឧទាហរណ៍ គ្រូត្រូវតែធ្វើការប្តេជ្ញាចិត្តនិងមានជំនឿចិត្តគ្រប់គ្រាន់ចំពោះសមត្ថភាពរបស់ខ្លួន ដែលថាខ្លួនអាចបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមប្រកបដោយភាពពិតឥតលម្អៀង និងដឹកនាំសិស្សឲ្យចាកឆ្ងាយពីវិវាទសម្បារ ។ សំខាន់ជាងនេះទៅទៀត ការគ្រប់គ្រងគុណភាពផ្តល់ឲ្យគ្រូនូវចំណេះដឹងនិងជំនឿចិត្តចំពោះសមត្ថភាពរបស់ខ្លួន ក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរ នៅក្នុងការបង្រៀនរបស់ខ្លួន ។ ការគ្រប់គ្រងគុណភាពមិនត្រឹមតែផ្តល់អនុសាសន៍ដើម្បីធ្វើឲ្យប្រសើរឡើងនោះទេ ប៉ុន្តែទាំងបន្តការគាំទ្រនិងការតាមដានថែមទៀត ដែលគ្រូអាចយកមកធ្វើជាការណែនាំបន្តបាន ។ ជាងនេះទៅទៀត គ្រូមានឱកាសសិក្សាពីគ្រូផ្សេងៗទៀត ។ គ្រូនឹងមានឱកាសក្នុងការរៀនពីគ្នាទៅវិញទៅមក ដោះដូរបទពិសោធន៍ និងបង្កើតវិធីសាស្ត្រក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរ ទៅលើទម្លាប់និងវិធីសាស្ត្របង្រៀនរបស់ខ្លួន ។

## ការគ្រប់គ្រងគុណភាពនៅក្នុងបរិបទគម្រោង

នៅក្នុងបរិបទនៃគម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ការគ្រប់គ្រងគុណភាពគឺជាដំណើរការនៃការវាយតម្លៃ ការស្ទង់មើល ការគ្រប់គ្រង ការធានា និងការធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅថ្នាក់មធ្យមសិក្សា នៅទូទាំងប្រទេសកម្ពុជា ។ បន្ទាប់មកទៀត ការគ្រប់គ្រងគុណភាពធានាឲ្យបានថា គម្រោងនៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ

នឹងសម្រេចបាននូវគោលដៅរបស់ខ្លួន នូវក្នុងការកសាងសន្តិភាព ការផ្សះផ្សាជាតិ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ជាសាកល ។ ការគ្រប់គ្រងគុណភាពនឹងត្រូវបានធ្វើឡើង ដោយប្រើប្រាស់វិធីសាស្ត្រការពិនិត្យពីខាងក្រៅ និងវិធីសាស្ត្រស្វ័យវាយតម្លៃ ដែលក្រសួងអប់រំយុវជននិងកីឡាបានប្រើប្រាស់នៅក្នុងការធ្វើការវាយតម្លៃរបស់ខ្លួន ។ ការគ្រប់គ្រងគុណភាពគឺជាផ្នែកមួយនៃការគ្រប់គ្រងគុណភាពអប់រំ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រសួងអប់រំយុវជននិងកីឡាគ្រប់គ្រង ក្នុងកំឡុងពេលនៃការអនុវត្តន៍គម្រោង ។

## ជំហានក្នុងការគ្រប់គ្រងគុណភាព




## គោលបំណងនៃការគ្រប់គ្រងគុណភាព

គោលបំណងចម្បងនៃគម្រោងក្នុងការគ្រប់គ្រងគុណភាពនេះ គឺដើម្បីរៀបចំគ្រូថ្នាក់មធ្យមសិក្សានៅកម្ពុជា ឲ្យបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យប្រកបដោយប្រសិទ្ធភាព ។ ប្រសិទ្ធភាពនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ត្រូវបានវាស់ស្ទង់ដោយកម្រិត ដែលគ្រូអាចយកចំណេះដឹង(ទៅលើខ្លឹមសារនៅក្នុងសៀវភៅប្រវត្តិសាស្ត្រ) និងជំនាញ(វិធីសាស្ត្រនៅក្នុងសៀវភៅណែនាំគ្រូនិងនៅក្នុងសម្ភារៈសិក្សាផ្សេងៗទៀត) ដែលខ្លួនទទួលបានពីវគ្គបណ្តុះបណ្តាល ទៅអនុវត្តនៅក្នុងថ្នាក់រៀនបាន ។ គ្រូគួរតែអាចផ្សា

ភ្ជាប់ខ្លឹមសារនៅក្នុងសៀវភៅប្រវត្តិសាស្ត្រ ទៅនឹងវិធីសាស្ត្រនៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ហើយប្រើប្រាស់សៀវភៅណែនាំគ្រូ ជាសម្ភារៈសិក្សាបន្ថែម ដើម្បីទ្រទ្រង់ការបង្រៀនសៀវភៅប្រវត្តិសាស្ត្រ ។ បន្ទាប់ពីវគ្គបណ្ដុះបណ្ដាលរួចមក មជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រសួងអប់រំយុវជននិងកីឡា និងធ្វើការវាយតម្លៃ ដើម្បីធានាឲ្យបានថា គ្រូមានលទ្ធភាពក្នុងការប្រើប្រាស់ចំណេះដឹង ជំនាញ និងឥរិយាបទដែលខ្លួនទទួលបានក្នុងកំឡុងពេលនៃវគ្គបណ្ដុះបណ្ដាល ហើយអាចអនុវត្តចំណេះដឹងនិងជំនាញទាំងនេះនៅក្នុងថ្នាក់រៀនបាន ។ ប្រសិទ្ធភាពនៃការបង្រៀនធានាឲ្យបានថា គ្រូអាចឆ្លើយទៅនឹងសំណួរអំពីគោលបំណងដែលបានបង្ហាញនៅក្នុងសៀវភៅណែនាំគ្រូ ៈ ហេតុអ្វីបានជាសិស្សត្រូវសិក្សាប្រវត្តិសាស្ត្រនេះ? តើអ្វីជាមេរៀនដ៏មានសារសំខាន់បំផុត ដែលសិស្សអាចរៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងពីអំពើប្រល័យពូជសាសន៍? តើការសិក្សាពីប្រវត្តិសាស្ត្រនេះ មានឥទ្ធិពលអ្វីខ្លះទៅលើអារម្មណ៍នៃចិត្តអាណិតអាសូរនិងមេត្តាករុណារបស់សិស្ស? ដោយគិតពីសំណួរទាំងនេះនៅក្នុងចិត្តគ្រូគួរតែអាចស្វែងយល់អំពីលក្ខខណ្ឌដែលអនុញ្ញាតឲ្យខ្មែរក្រហមឡើងកាន់អំណាចបាន គោលនយោបាយនិងមនោគមវិជ្ជា ដែលបង្កការឈឺចាប់មកលើប្រជាជននិងនាំមកនូវការបំផ្លិចបំផ្លាញយ៉ាងធំធេងមកលើប្រទេសជាតិ និងផលប៉ះពាល់ដែលជាលទ្ធផលនៃការអនុវត្តន៍គោលនយោបាយនិងមនោគមវិជ្ជាទាំងនេះ ។ ធ្វើដូច្នេះ គ្រូអាចជួយសិស្សឲ្យធ្វើការផ្សារភ្ជាប់អត្ថន័យនៅក្នុងសៀវភៅ ទៅនឹងបរិបទនៃជីវិតរបស់ខ្លួននាពេលបច្ចុប្បន្ន និងអភិវឌ្ឍទំនាក់ទំនងរវាងជំនាន់មួយទៅជំនាន់មួយទៀត គឺរវាងសិស្សនិងសាច់ញាតិចាស់ៗរបស់ខ្លួន ។ គ្រូគួរតែអាចណែនាំសិស្សទៅកាន់មក្រិតមួយ ដែលសិស្សអាចបង្ហាញពីសមត្ថភាពក្នុងការធ្វើបទបង្ហាញនៅក្នុងថ្នាក់ សរសេររបាយការណ៍និងតែងសេចក្ដី រក្សាសៀវភៅកំណត់ហេតុ ធ្វើការសិក្សាប្រៀបធៀប ក៏ដូចជាអភិវឌ្ឍជំនាញក្នុងការត្រិះរិះពិចារណា ដែលជំនាញទាំងអស់នេះមានរៀបរាប់លម្អិតនៅក្នុងសៀវភៅណែនាំគ្រូ ។ ការវាយតម្លៃនឹងធ្វើការផ្ដល់យោបល់ ដើម្បីឲ្យការបង្រៀនរបស់គ្រូកាន់តែមានលក្ខណៈល្អប្រសើរឡើង ។

បទពិសោធន៍នៃការងារវាយតម្លៃរបស់ក្រសួងអប់រំយុវជននិងកីឡា បានជួយយើងយ៉ាងច្រើននៅក្នុងការផលិតសៀវភៅគ្រប់គ្រងគុណភាព និងការអនុវត្តគម្រោងនេះដោយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាគ្រូថ្នាក់ជាតិ និងអ្នកជំនាញបរទេសជាច្រើនរូប ដែលនឹងដើរតួជាអ្នកវាយតម្លៃ ទៅលើសាលាមធ្យមសិក្សាចំនួន២០០សាលានៅទូទាំងប្រទេស ។ អ្នកវាយតម្លៃទទួលខុសត្រូវជួយគ្រូបង្រៀនឲ្យយល់ថាតើដំណើរការនៃការគ្រប់គ្រងគុណភាពនឹងធ្វើឲ្យគ្រូពង្រីកការបង្រៀន និងជំនាញអាជីពរបស់ខ្លួនខណៈពេលដែលគ្រូបង្រៀន “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ” ។ យោងតាមបទពិសោធន៍របស់ក្រសួងអប់រំយុវជននិងកីឡា ក្រុមអធិការកិច្ចដែលធ្វើការជាមួយគ្រូនៅតាមមូលដ្ឋានអស់ជាច្រើនឆ្នាំបានបញ្ជាក់ថា ការបង្កើតចំណាប់អារម្មណ៍វិជ្ជមាន គឺជាកត្តាដ៏មានសារសំខាន់មួយនៅក្នុងការអនុវត្តន៍ការគ្រប់គ្រងគុណភាព ។ ការទទួលបានការទុកចិត្តនិងជំនឿចិត្តពីគ្រូ ហើយការធ្វើឲ្យគ្រូក្លាយទៅជាផ្នែកមួយនៃដំណើរការគ្រប់គ្រងគុណភាព គឺជាជំហានដ៏មាន

សារសំខាន់មួយនៅក្នុងកិច្ចការនេះ ។ ការទទួលបានចម្លើយត្រង់ៗ និងច្បាស់លាស់ពីគ្រូរួមចំណែកដល់ការវាយតម្លៃពីគុណភាព និងធានាដល់ការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព ដើម្បីធ្វើឲ្យប្រសើរឡើងដល់ការគ្រប់គ្រងគុណភាពអប់រំទាំងមូល ។

## ផែនការនិងកាលបរិច្ឆេទនៃការគ្រប់គ្រងគុណភាព

ក្រុមអ្នកវាយតម្លៃនឹងចំណាយពេលមួយខែនៅក្នុងខេត្តនីមួយៗ និងមួយសប្តាហ៍នៅតាមសាលានីមួយៗ ។ ក្រុមពីរដែលមានសមាជិកពីរនាក់ក្នុងមួយក្រុម (បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាម្នាក់ និងគ្រូខេត្តថ្នាក់ជាតិម្នាក់) នឹងទទួលខុសត្រូវក្នុងការវាយតម្លៃក្នុងខេត្តនីមួយៗ ។ ការជ្រើសរើសគ្រូសម្រាប់ធ្វើការវាយតម្លៃនឹងមិនចោទជាបញ្ហាអ្វីទេ សម្រាប់ក្រុមវាយតម្លៃដោយសារសាលានីមួយៗមានគ្រូប្រវត្តិវិទ្យាពីបីទៅបួននាក់ និង គ្រូផ្សេងៗទៀតដែលបង្រៀនមុខវិជ្ជាភាសាខ្មែរនិងសីលធម៌ពលរដ្ឋ ។ នៅក្នុងមួយសប្តាហ៍អ្នកវាយតម្លៃអាចធ្វើការសង្កេតមើលការបង្រៀនរបស់គ្រូប្រវត្តិវិទ្យាទាំងអស់ ។ នៅក្នុងករណីសាលាធំ ដែលមានគ្រូប្រវត្តិវិទ្យារហូតដល់ទៅដាំងដប់នាក់អ្នកវាយតម្លៃអាចប្រើប្រាស់វិធីសាស្រ្តនៃការជ្រើសរើសគំរូចម្រុះធម្មតា ដែលជាភាសាអង់គ្លេសហៅថា (simple random sampling) ដើម្បីជ្រើសរើសគ្រូចំនួនបួនរូបដែលការជ្រើសរើស នេះត្រូវប្រើវិធីសាស្រ្តទាញយកដោយចៃដន្យ ឬជាភាសាអង់គ្លេសហៅថា (fishbowl draw) ។ មានហានិភ័យតិចតួចណាស់ ដែលថាគ្រូមួយចំនួននឹងបដិសេធមិនចូលរួមដោយសារកិច្ចការនេះគឺជាកិច្ចសហការរវាងក្រសួងអប់រំយុវជននិងកីឡាដែលគ្រូមានកាតព្វកិច្ចត្រូវតែចូលរួម ។ ប្រសិនបើគ្រូណាមួយមិនអាចចូលរួម ដោយសារហេតុផលផ្សេងៗ (ឧទាហរណ៍ គ្រូខ្វះឈឺឬនៅឆ្ងាយពីសាលា) អ្នកវាយតម្លៃអាចជ្រើសរើសគ្រូមួយទៀតដោយមិនចំពោះ ។

### ផែនការមេសម្រាប់ការគ្រប់គ្រងគុណភាព

| ខេត្ត | ក្រុម | សាលា | អ្នកវាយតម្លៃ | កាលបរិច្ឆេទ |
|---|---|---|---|---|
| ខេត្តទី១ | ក្រុមទី១ | សាលាទី១ | បុគ្គលិក DC-Cam ម្នាក់ និងគ្រូថ្នាក់ជាតិម្នាក់ | សប្តាហ៍ទី១ |
| | | សាលាទី២ | បុគ្គលិក DC-Cam ម្នាក់ និងគ្រូថ្នាក់ជាតិម្នាក់ | សប្តាហ៍ទី២ |
| | | សាលាទី៣ | បុគ្គលិក DC-Cam ម្នាក់ និងគ្រូថ្នាក់ជាតិម្នាក់ | សប្តាហ៍ទី៣ |
| | | សាលាទី៤ | បុគ្គលិក DC-Cam ម្នាក់ និងគ្រូថ្នាក់ជាតិម្នាក់ | សប្តាហ៍ទី៤ |
| | ក្រុមទី២ | សាលាទី១ | បុគ្គលិក DC-Cam ម្នាក់ និងគ្រូថ្នាក់ជាតិម្នាក់ | សប្តាហ៍ទី១ |
| | | សាលាទី២ | បុគ្គលិក DC-Cam ម្នាក់ និងគ្រូថ្នាក់ជាតិម្នាក់ | សប្តាហ៍ទី២ |
| | | សាលាទី៣ | បុគ្គលិក DC-Cam ម្នាក់ និងគ្រូថ្នាក់ជាតិម្នាក់ | សប្តាហ៍ទី៣ |

| | | សាលាទី៤ | បុគ្គលិក DC-Cam ម្នាក់ និងគ្រូថ្នាក់ជាតិម្នាក់ | សប្តាហ៍ទី៤ |
|---|---|---|---|---|

## ក្រុមវាយតម្លៃ

គុណភាពនៃការវាយតម្លៃពឹងផ្អែកយ៉ាងច្រើន នៅលើជំនាញនិងបុគ្គលិកដែលអនុវត្តកិច្ចការគ្រប់គ្រងគុណភាព។ ដូច្នេះ ការគ្រប់គ្រងគុណភាពនឹងត្រូវបានធ្វើឡើងដោយមនុស្សបីក្រុម ដែលបានចូលរួមនៅក្នុងគម្រោងតាំងពីការចាប់ផ្តើម និងដែលមានបទពិសោធន៍ច្រើននៅក្នុងការអប់រំ ការអភិវឌ្ឍន៍កម្មវិធីសិក្សា ការសិក្សាពីអំពើប្រល័យពូជសាសន៍ និងការវាយតម្លៃ។ អ្នកទាំងនេះរួមមាន ៖

- បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ
- គ្រូថ្នាក់ជាតិពីក្រសួងអប់រំយុវជននិងកីឡាចំនួន២៤រូប
- អ្នកជំនាញបរទេសចំនួន១០រូប ។

ដើម្បីធ្វើការគ្រប់គ្រងគុណភាពឲ្យមានប្រសិទ្ធភាព អ្នកវាយតម្លៃត្រូវតែច្បាស់អំពីអ្វីដែលខ្លួននឹងត្រូវធ្វើតួនាទី និងការទទួលខុសត្រូវ ។ ជាងនេះទៅទៀត អ្នកវាយតម្លៃត្រូវតែយល់ ថាតើចំណេះដឹងនិងជំនាញអ្វីខ្លះដែលខ្លួនត្រូវមាន ដើម្បីអនុវត្តតួនាទីនិងការទទួលខុសត្រូវរបស់ខ្លួនឲ្យបានជោគជ័យ ។ មិនមានការជ្រើសរើសទេនៅក្នុងបរិបទនេះ ។ តារាងខាងក្រោមរៀបរាប់អំពីតួនាទី ការទទួលខុសត្រូវ គុណសម្បត្តិដែលអ្នកវាយតម្លៃត្រូវមាន ។

| **តួនាទីនិងការទទួលខុសត្រូវរបស់អ្នកវាយតម្លៃ** |
|---|
| ▪ ចូលរួមនៅក្នុងសិក្ខាសាលាស្តីពីការគ្រប់គ្រងគុណភាព ។<br>▪ ចូលរួមនៅក្នុងកិច្ចប្រជុំនិងការពិភាក្សា ដើម្បីស្វែងយល់គោលដៅទូទៅ និងគោលបំណងនៃការគ្រប់គ្រងគុណភាព ។<br>▪ អាននិងពិនិត្យមើលរាល់ឯកសារពាក់ព័ន្ធ និងឧបករណ៍ក្នុងការវាយតម្លៃ ។<br>▪ ធ្វើដំណើរទៅកាន់សាលាមធ្យមសិក្សាដែលបានកំណត់ ដើម្បីធ្វើការអង្កេតនិងប្រមូលទិន្នន័យ ។<br>▪ សរសេររបាយការណ៍ពីការចុះទៅតាមសាលារបស់ខ្លួន ។<br>▪ អាននិងវិភាគរាល់ទិន្នន័យសម្រាប់ធ្វើការវាយតម្លៃ ដែលប្រមូលបាន ។<br>▪ ធ្វើការវាយតម្លៃ និងផ្តល់អនុសាសន៍ដើម្បីធ្វើការកែលម្អ ។<br>▪ ចូលរួមនៅក្នុងការពិនិត្យតាមដាន ។ |
| **អ្នកវាយតម្លៃគួរតែមានគុណសម្បត្តិដូចខាងក្រោម** |
| ▪ មានចំណេះដឹងពីគម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីធ្វើការគ្រប់គ្រងគុណភាព ។ |

- មានបទពិសោធន៍ទៅលើចំណុចមួយចំនួននៃការសិក្សាពីអំពើប្រល័យពូជសាសន៍ ការអភិវឌ្ឍន៍កម្មវិធី ការគ្រប់គ្រងគុណភាព និងការគ្រប់គ្រងការអប់រំ ។
- អាចវិភាគនិងធ្វើការវាយតម្លៃដែលអាចជឿទុកចិត្តបានទៅលើព័ត៌មាន និងទៅលើទិន្នន័យដែលប្រមូលបានពីសាលា ។
- ចូលរួមនៅក្នុងការបង្រៀន ការស្រាវជ្រាវ និងស្ថាប័នសិក្សា ។

## ការអនុវត្តន៍ការគ្រប់គ្រងគុណភាព ៖ វិធីសាស្ត្រក្នុងការវាយតម្លៃ

ដើម្បីអនុវត្តការគ្រប់គ្រងគុណភាពប្រកបដោយប្រសិទ្ធភាព វាមានសារសំខាន់ណាស់ក្នុងការប្រើប្រាស់វិធីសាស្ត្រ ដែលអាចទទួលបាននូវអនុសាសន៍ជាក់ស្តែង ដើម្បីធ្វើឲ្យប្រសើរឡើងនូវវគ្គបណ្តុះបណ្តាលគ្រូជាបន្តបន្ទាប់ទៀត និងការបង្រៀននៅក្នុងថ្នាក់រៀន។ និយាយម្យ៉ាងទៀត អ្នកវាយតម្លៃត្រូវធ្វើការស៊ើបអង្កេតទៅលើឥទ្ធិពល ដែលការបណ្តុះបណ្តាលដើម្បីអភិវឌ្ឍជំនាញមានទៅលើការអនុវត្តន៍ការបង្រៀន ការរៀនរបស់សិស្ស និងទៅលើសាលារៀន និងសហគមន៍ទាំងមូល ។ វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ដើម្បីអនុវត្តការគ្រប់គ្រងគុណភាព ត្រូវបានគាក់តែងឡើង ដើម្បីសម្រេចឲ្យបាននូវគោលបំណងរបស់គម្រោង ។ នៅក្នុងន័យនេះ គោលបំណងរបស់គម្រោងគឺជាកញ្ចក់ឆ្លុះបញ្ចាំង ដែលអ្នកវាយតម្លៃប្រើប្រាស់ដើម្បីធ្វើការវិភាគអំពីគុណភាពនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងរយៈពេលនៃការអនុវត្តន៍ការវាយតម្លៃ អ្នកវាយតម្លៃគួរតែអាចឆ្លើយទៅនឹងសំណួរដូចខាងក្រោម ៖

១. តើគ្រូអាចអនុវត្តចំណេះដឹង ជំនាញ និងវិធីសាស្ត្របង្រៀន ដែលខ្លួនទទួលបានពីវគ្គបណ្តុះបណ្តាលគ្រូនៅក្នុងថ្នាក់រៀនបានដែរឬទេ?

២. តើគ្រូអាចប្រើប្រាស់សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងថ្នាក់រៀនបានកម្រិតណា?

៣. តើគ្រូអាចអនុវត្តវិធីសាស្ត្រ ដែលមានចែងនៅក្នុងសៀវភៅណែនាំគ្រូ នៅក្នុងការបង្រៀនរបស់ខ្លួនបានដែរឬទេ?

៤. តើគ្រូមានពេលវេលានិងឱកាស ក្នុងការប្រើប្រាស់សម្ភារៈសិក្សាបន្ថែម ដែលត្រូវបានផ្តល់ឲ្យនៅក្នុងវគ្គបណ្តុះបណ្តាលដែរឬទេ?

៥. តើគ្រូអាចប្រើប្រាស់ចំណេះដឹង ដែលខ្លួនទទួលបានពីវគ្គបណ្តុះបណ្តាល នៅក្នុងថ្នាក់រៀនបានត្រឹមកម្រិតណា?

៦. តើគ្រូអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព នៅក្នុងបរិបទនៃបរិយាកាសក្នុងថ្នាក់រៀនរបស់ខ្លួនបានដែរឬទេ?

៧. តើគ្រូយល់ដឹងអំពីការអនុវត្តន៍ការបង្រៀនរបស់ខ្លួនដោយរបៀបណា បើប្រៀបធៀបទៅនឹងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមកាលពីមុន?

៨. តើបញ្ហាប្រឈមអ្វីខ្លះដែលគ្រូជួបប្រទះ ក្នុងការប្រើប្រាស់ចំណេះដឹង ជំនាញ និងសម្ភារៈបង្រៀននៅក្នុងកំឡុងពេលនៃការបង្រៀនរបស់ខ្លួន ។

## វិធីសាស្ត្រក្នុងការវាយតម្លៃ

**ក. ការអង្កេតថ្នាក់រៀន** គឺជាវិធីដ៏ល្អមួយ នៅក្នុងការមើលនិងស្តាប់ការអនុវត្តការបង្រៀន សកម្មភាពនៅក្នុងការរៀននិងបង្រៀន និងសកម្មភាពផ្សេងៗទៀតនៅក្នុងថ្នាក់រៀន ។ ការអង្កេតគឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពនៅក្នុងការប្រមូលទិន្នន័យ នៅពេលអ្នកចង់ធ្វើការសិក្សាការអនុវត្តន៍ការបង្រៀនរបស់គ្រូ នៅក្នុងពេលដែលព័ត៌មានពិត មិនអាចទទួលយកបានតាមរយៈសំណួរស្ទាបស្ទង់ ។ ក្រុមវាយតម្លៃប្រើប្រាស់វិធីសាស្ត្រអង្កេតប្រកបដោយការចូលរួម ដែលអ្នកវាយតម្លៃ ចូលរួមនៅក្នុងដំណើរការបង្រៀននិងរៀននៅក្នុងថ្នាក់រៀនទាំងស្រុង ។

**ខ. សំណួរស្ទាបស្ទង់** គឺជាបញ្ជីសំណួរជាលក្ខណៈសំណេរមួយ ដែលចម្លើយទៅនឹងសំណួរទាំងនេះត្រូវបានផ្តល់ឲ្យដោយគ្រូនិងសិស្ស ដែលជាអ្នកចូលរួមនៅក្នុងការគ្រប់គ្រងគុណភាព ។ ដោយប្រើប្រាស់សំណួរស្ទាបស្ទង់ គ្រូអាចឆ្លើយតបដោយឯករាជ្យនិងជាឯកជន ទៅនឹងសំណួរនីមួយៗ ។ ដូច្នេះ សំណួរត្រូវតែច្បាស់និងងាយយល់ ។ ទម្រង់នៃសំណួរស្ទាបស្ទង់មានការរៀបចំបានល្អ ហើយលំដាប់លំដោយនៃសំណួរមានការងាយស្រួលក្នុងការតាមដាន ។ សំណួរអាចមានច្រើនទម្រង់ផ្សេងៗគ្នាដូចជា សំណួរទម្រង់បិទ ពហុជ្រើសរើស និងការឲ្យកម្រិតទៅលើប្លូនកម្រិត ។ សំណួរមួយចំនួនទៀតគឺជាសំណួរទម្រង់បើក ។ សំណួរទាំងអស់បង្ហាញដោយផ្ទាល់ពីបញ្ហាដែលមាន ទៅលើអត្ថន័យនិងរចនាសម្ព័ន្ធនៅក្នុងសៀវភៅប្រវត្តិសាស្ត្រ សៀវភៅណែនាំសម្រាប់គ្រូបង្រៀន និងសៀវភៅលំហាត់សម្រាប់សិស្ស ។ សំណួរទាំងអស់ពិនិត្យមើល ថាតើសំណេរនិងខ្លឹមសារនៅក្នុងសៀវភៅប្រវត្តិសាស្ត្រ មានភាពពិតឥតលម្អៀងនិងលម្អិតគ្រប់គ្រាន់ សម្រាប់ចំណេះដឹងរបស់សិស្សទៅលើប្រវត្តិសាស្ត្រខ្មែរក្រហម និងសមសម្រាប់សិស្សកម្រិតមធ្យមសិក្សាដែរឬយ៉ាងណា ។ ចំពោះរចនាសម្ព័ន្ធរបស់សៀវភៅ សំណួរធ្វើការវាយតម្លៃ ថាតើរូបភាពនិងអត្ថន័យមានភាពច្បាស់លាស់ និងគាំទ្រគ្នាទៅវិញទៅមកឬយ៉ាងណា ។ ដូចគ្នាដែរ សំណួរពិនិត្យមើលទៅលើបញ្ហាប្រហាក់ប្រហែលគ្នា ស្តីអំពីខ្លឹមសារនៃវិធីសាស្ត្រនិងរូបភាព ដែលមាននៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀននិងសៀវភៅលំហាត់សម្រាប់សិស្ស ។ សំណួរស្ទាបស្ទង់នឹងពិនិត្យមើល ថាតើគោលដៅអប់រំ វិធីសាស្ត្រ និងលំហាត់ដែលបានបង្ហាញនៅក្នុងសម្ភារៈឧបទេសទាំងនេះ មានភាពច្បាស់លាស់ និងជួយសម្រួលដល់ការសិក្សារបស់សិស្ស ឲ្យក្លាយទៅជាអ្នករៀន

ឯករាជ្យ និងអ្នកគិតប្រកបដោយការត្រិះរិះពិចារណាដែរទេ។ ពិសេសជាងនេះទៅទៀត សំណួរស្ទាបស្ទង់និង ពិនិត្យមើល ថាតើសៀវភៅណែនាំសម្រាប់គ្រូបង្រៀន និងសៀវភៅលំហាត់សម្រាប់សិស្ស គាំទ្រសៀវភៅ ប្រវត្តិសាស្ត្រ នៅក្នុងដំណើរការនៃការរៀនដែរឬទេ។

**គ. បទសម្ភាសន៍** នៅក្នុងបរិបទនេះ គឺជាការឆ្លើយឆ្លងទល់មុខគ្នារវាងអ្នកសម្ភាសនិងអ្នកផ្តល់បទសម្ភាសន៍ ដើម្បីទទួលបាននូវព័ត៌មានលម្អិតបន្ថែមទៀត ទៅលើផ្នត់គំនិតរបស់មនុស្ស ការយល់ឃើញ និងទស្សនទាក់ទង ទៅនឹងបទពិសោធន៍នៅក្នុងថ្នាក់រៀន។ ការគ្រប់គ្រងគុណភាពនឹងត្រូវបានធ្វើឡើង ដោយប្រើប្រាស់បទ សម្ភាសន៍ក្នុងទម្រង់ ដែលសំណួរត្រូវបានបង្កើតនិងផ្តល់ឲ្យហើយជាស្រេច ដូច្នេះ អ្នកវាយតម្លៃអាចទទួលបាន ព័ត៌មានដែលមានទម្រង់តែមួយ ដែលងាយស្រួលក្នុងការវិភាគ និងធានាបាននូវភាពដែលអាចប្រៀបធៀប បាន។ បទសម្ភាសន៍ផ្តល់ឲ្យនូវព័ត៌មានស៊ីជម្រៅ ដោយសារអ្នកវាយតម្លៃមានឱកាសពន្យល់សំណួរ និងអាច សួរសំណួរបញ្ជាក់ម្តងទៀត។

**ឃ. សម្ភារៈបន្ថែម** គឺជាសម្ភារៈទាំងឡាយណា ដែលទាក់ទងទៅនឹងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជា ធិបតេយ្យ។ ឧទាហរណ៍មួយនៃសម្ភារៈបន្ថែមនេះ គឺសំណុំឯកសាររបស់សិស្ស ដែលមានណែនាំនៅក្នុង សៀវភៅណែនាំសម្រាប់គ្រូបង្រៀន។ សម្ភារៈផ្សេងៗទៀតរួមមានក្រដាសប្រលងរបស់សិស្ស ការងារធ្វើ នៅផ្ទះ និងបទសម្ភាសន៍របស់សិស្សជាមួយឪពុកម្តាយ សាច់ញាតិ និងអ្នកជិតខាង។

## សេចក្តីបញ្ចប់

ការគ្រប់គ្រងគុណភាពគឺជាជំហានទីបី នៅក្នុងដំណាក់កាលបីជំហានចម្បងៗ នៃគម្រោងស្តីពីការសិក្សា ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលមានបំណងដាក់បញ្ចូលការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប តេយ្យទៅក្នុងកម្មវិធីសិក្សារបស់សាលាមធ្យមសិក្សា នៅក្នុងប្រទេសកម្ពុជា។ ជោគជ័យនៃវគ្គបណ្តុះបណ្តាល គ្រូបីដំណាក់កាល (វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្ត និងវគ្គបណ្តុះ បណ្តាលគ្រូថ្នាក់មូលដ្ឋាន) គឺជាសញ្ញាចង្អុលបង្ហាញមួយ ដែលធានាឲ្យបានថា ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យ នឹងត្រូវបានធ្វើឡើងនៅក្នុងថ្នាក់រៀនក្នុងប្រទេសកម្ពុជា ជាមួយនឹងវិធីសាស្ត្រថ្មី និងអនុ លោមទៅតាមបទដ្ឋានគរុកោសល្យ ដែលបង្កើតឲ្យមានការត្រិះរិះពិចារណានិងស្វ័យសិក្សា។

ដើម្បីធានាឲ្យបាននូវការវិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រសិទ្ធភាពនៃការបង្រៀនរបស់គ្រូត្រូវតែធ្វើការវាយតម្លៃ។ ទោះបីជាគ្រូធ្វើការដោយអនុលោមទៅតាម គោលនយោបាយអប់រំ និងកម្មវិធីសិក្សាដែលត្រូវបានអនុម័តគ្រូបង្រៀនគឺជាតួអង្គដ៏សំខាន់នៅក្នុងការរៀបចំ

បរិស្ថាននៅក្នុងថ្នាក់រៀន រៀបចំការរៀនរបស់សិស្ស និងគ្រប់គ្រងផែនការនិងរចនាសម្ព័ន្ធទាំងមូលនៃដំណើរការនៅក្នុងការរៀននិងបង្រៀន។ គឺគ្រូបង្រៀននេះហើយ ដែលជាអ្នកអនុវត្តកិច្ចការបង្រៀននៅនឹងមូលដ្ឋានដើម្បីធានាឲ្យបានថា គោលដៅនិងគោលបំណងរបស់គម្រោងអាចសម្រេចទៅបាន។ ដូច្នេះ ការធ្វើការវាយតម្លៃ ការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ ដើម្បីកំណត់ភាពខ្លាំងនិងភាពខ្សោយ ទាំងនៅក្នុងវគ្គបណ្តុះបណ្តាល និងទាំងនៅក្នុងការយកខ្លឹមសារនៃវគ្គបណ្តុះបណ្តាលទៅអនុវត្ត គឺមានសារសំខាន់ ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពនៃការបង្រៀន។

ការវាយតម្លៃនឹងផ្តល់លទ្ធផលដ៏មានសារសំខាន់។ បន្ថែមពីលើការពិនិត្យមើលប្រសិទ្ធភាពនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ការវាយតម្លៃផ្តល់ឲ្យនូវភស្តុតាង ដើម្បីធ្វើការវាយតម្លៃឥទ្ធិពលដែលគម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ មានទៅលើគ្រូបង្រៀន សិស្ស និងឪពុកម្តាយ និងប្រទេសមួយទាំងមូល។ ការរកឃើញមិនត្រឹមតែផ្តល់ឲ្យគ្រូបង្រៀននូវវេទិកាមួយ ដើម្បីត្រឡប់ទៅមើលការអនុវត្តន៍របស់ខ្លួនកាលពីអតីតកាល ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងប៉ុណ្ណោះទេ ថែមទាំងអាចឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រសួងអប់រំយុវជននិងកីឡា ពិនិត្យមើលឡើងវិញនូវគោលដៅនិងគោលបំណងរបស់គម្រោង ដើម្បីកំណត់លទ្ធផលនៃការអនុវត្តន៍គម្រោង។ ជាងនេះទៅទៀត ការរកឃើញនឹងជួយឲ្យបុគ្គលពាក់ព័ន្ធផ្សេងៗទៀត យល់ពីគម្រោងនិងលទ្ធផល ដើម្បីជួយសម្រេចឲ្យបាននូវគោលដៅរបស់គម្រោងទូលំទូលាយជាងនេះបន្ថែមទៀត។ ប្រសិទ្ធភាពនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ធានាសម្រេចឲ្យបាននូវការកសាងសន្តិភាព ការផ្សះផ្សាជាតិ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ជាសាកល។ មកត្រឹមចំណុចនេះ គម្រោងនៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ នឹងអាចចាប់ផ្តើមបង្កើតឲ្យមានយន្តការទូលំទូលាយនិងប្រសិទ្ធភាពមួយ ជំនួសឲ្យតួនាទីគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សានៅកម្ពុជា៕